# ឯកសារសង្ខេបអំពីផែនការអនុវត្តជាយុទ្ធសាស្ត្រ

# ផ្នែក ការស្តារលទ្ធភាពពលកម្ម

World Health Organization Cambodia

## សង្ខេបគម្រោង

នៅខែធ្នូ ឆ្នាំ ២០២២ អង្គការសុខភាពពិភពលោក (WHO) បានចេញផ្សាយរបាយការណ៍សកលស្តីពីសមធម៌ផ្នែកសុខភាពសម្រាប់ជនមានពិការភាព។ របាយការណ៍នេះបានវិភាគលើប្រព័ន្ធនៃវិសមភាពផ្នែកសុខភាពសម្រាប់ជនមានពិការភាព និងផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ឧបសគ្គដែលជនមានពិការភាពប្រឈមក្នុងការទទួលបាននូវសុខភាពកាន់តែល្អប្រសើរ មានលើសពីនេះ ក៏ដូចជានៅក្នុងវិស័យសុខាភិបាល។ បញ្ហាប្រឈមទាំងនេះរួមមានគ្រប់ទម្រង់នៃការទទួលបានសេវាថែទាំសុខភាពនៅទូទាំងការថែទាំបន្ត រាប់ចាប់តាំងពីការទទួលបានសារលើកកម្ពស់សុខភាព និងកិច្ចអន្តរាគមន៍នានាតាមរយៈការផ្តល់សេវាសុខាភិបាលដែលបំពេញតម្រូវការទាំងអស់របស់បុគ្គលម្នាក់ៗពេញមួយជីវិតរបស់ពួកគាត់ រហូតដល់សេវាស្តារលទ្ធភាពពលកម្មផ្សេងៗ ដែលមិនទាន់អាចរកបានឱ្យទូលំទូលាយនៅឡើយ។

នៅទូទាំងពិភពលោក មានមនុស្សម្នាក់ក្នុងចំណោមបីនាក់ត្រូវការសេវាស្តារលទ្ធភាពពលកម្មនៅពេលវេលាណាមួយនៃវដ្តជីវិតរបស់គេ។ ទោះបីជាមានប្រសិទ្ធភាពនៃសេវាស្តារលទ្ធភាពពលកម្មក្នុងការធ្វើឱ្យប្រសើរឡើងនូវមុខងាររាងកាយ ផ្លូវចិត្ត និងសុខុមាលភាព ព្រមទាំងក្នុងការទប់ស្កាត់ផលវិបាកដែលទាក់ទងនឹងស្ថានភាពស្រួចស្រាវ និងរ៉ាំរ៉ៃក៏ដោយ ក៏នៅតែមានតម្រូវការដ៏ធំមួយសម្រាប់សេវាស្តារលទ្ធភាពពលកម្ម គួបផ្សំនឹងការវិនិយោគ និងការយល់ដឹងដែលនៅមានកម្រិតទាបនៅឡើយ។ គំនិតផ្តួចផ្តើមនៃការស្តារលទ្ធភាពពលកម្មរបស់អង្គការសុខភាពពិភពលោក ឆ្នាំ២០៣០ បានបង្ហាញពីសារៈសំខាន់នៃការពង្រឹងប្រព័ន្ធសុខាភិបាល ដើម្បីផ្តល់ការស្តារលទ្ធភាពពលកម្មឱ្យទៅជាផ្នែកសំខាន់មួយនៃការគ្របដណ្តប់សុខភាពជាសកល (UHC)។

ក្នុងក្របខណ្ឌនៃកម្មវិធី ACCESS 2 ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) គាំទ្រតួនាទីមួយរបស់អង្គការសុខភាពពិភពលោកនៅប្រទេសកម្ពុជា ដោយផ្តោតលើសមធម៌សុខភាពសម្រាប់ជនមានពិការភាព និងការពង្រឹងការស្តារ

លទ្ធភាពពលកម្មក្នុងប្រព័ន្ធសុខាភិបាល។ តួនាទីនេះនឹងរួមចំណែកយ៉ាងសំខាន់ដល់តួនាទី និងគោលនយោបាយ និងផែនការជំនួយរបស់អង្គការសុខភាពពិភពលោកនៅកម្ពុជា ឆ្ពោះទៅរកសមធម៌សុខភាពសម្រាប់ជនមានពិការភាព និងការពង្រឹងការស្តារលទ្ធភាពពលកម្មតាមរយៈ៖

១. គាំទ្រដល់ការអភិវឌ្ឍន៍ ការពិនិត្យតាមដានការអនុវត្ត និងការវាយតម្លៃផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាពរបស់ក្រសួងសុខាភិបាល ស្តីពីពិការភាពក្នុងវិស័យសុខាភិបាល។

២. ការវាយតម្លៃ និងយុទ្ធសាស្ត្រនានា ដើម្បីជួយសម្រួលដល់ការធ្វើសមាហរណកម្ម និងការពង្រឹងការស្តារលទ្ធភាពពលកម្មនៅក្នុងប្រព័ន្ធសុខាភិបាល និងការពង្រីកលទ្ធភាពទទួលបានបច្ចេកវិទ្យាជំនួយ រួមទាំងភស្តុតាង និងដំបូន្មានផ្នែកបច្ចេកទេសស្តីពីជម្រើសសម្រាប់ហិរញ្ញប្បទានសេវាស្តារលទ្ធភាពពលកម្ម។

៣. ការធានាបាននូវបរិយាបន្នពិការភាព និងការពិចារណាលើការស្តារលទ្ធភាពពលកម្មនៅក្នុងគោលនយោបាយ ចម្បង កញ្ចប់ស្តារ គោលការណ៍ណែនាំ និងសកម្មភាពសំខាន់ៗផ្សេងទៀតឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅក្នុងប្រទេសកម្ពុជា។

អង្គការសុខភាពពិភពលោកនៅកម្ពុជានឹងសហការជាមួយដៃគូផ្សេងទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងនានា រួមទាំងដៃគូរបស់ ACCESS 2 ក៏ដូចជាប្រើប្រាស់ធនធានបច្ចេកទេស ជំនាញ និងការគាំទ្ររបស់ WHO ជាសកល ក្នុងតំបន់ និងថ្នាក់ជាតិ។

## លទ្ធផលនៃគម្រោង

- ការជ្រើសរើសបុគ្គលិកជំនាញជនជាតិខ្មែរដែលមានសក្តានុពលខ្ពស់ដើម្បីបំពេញការងារផ្នែកពិការភាព និងការស្តារលទ្ធភាពពលកម្ម ដែលអាចជួយគាំទ្រការណែនាំផ្នែកគុណភាពបច្ចេកទេសពាក់ព័ន្ធ ដែល WHO ផ្តល់ដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- រៀបចំឯកសារបច្ចុប្បន្នភាពស្ថានភាព និងប្រព័ន្ធវាយតម្លៃពីតម្រូវការ និងលទ្ធភាពទទួលបានសេវាស្តារលទ្ធភាពពលកម្ម រួមជាមួយបច្ចេកវិទ្យានៃគ្រឿងជំនួយក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមចំណែកជាព័ត៌មានក្នុងការរៀបចំគោលនយោបាយ ផែនការ និងការស្វែងរកការគាំទ្រមតិ
- សមាហរណកម្មបរិយាបន្នពិការភាព និងការស្តារលទ្ធភាពពលកម្មកាន់តែប្រសើរជាងមុននៅក្នុងយុទ្ធសាស្ត្រ ផែនការ គោលការណ៍ណែនាំ និងកញ្ចប់សេវា និងការផ្តល់សេវាក្នុងវិស័យសុខាភិបាលនៃប្រទេសកម្ពុជា

- យុទ្ធសាស្ត្រ និងគោលនយោបាយស្តីពីពិការភាពក្នុងវិស័យសុខាភិបាលត្រូវបានបង្កើតឡើង និងអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃឆ្ពោះទៅរកសមធម៌សុខភាពសម្រាប់ជនមានពិការភាពក្នុងប្រទេសកម្ពុជា
- ការរួមបញ្ចូល ការស្តារលទ្ធភាពពលកម្ម និងបរិយាបន្នពិការភាពក្នុងក្របខណ្ឌ និងយន្តការពិនិត្យតាមដាននៃប្រព័ន្ធសុខាភិបាលកម្ពុជាត្រូវបានបង្ហាញឱ្យឃើញកាន់តែច្រើនឡើង។
- ការពិចារណាជាក់លាក់លើការការពារសុខភាពរបស់ជនមានពិការភាព ដើម្បីដាក់រួមបញ្ចូលទៅក្នុងផែនការត្រៀមលក្ខណៈសង្គ្រោះបន្ទាន់ផ្នែកសុខភាព និងផែនការឆ្លើយតប និងការវាយតម្លៃ។

## សកម្មភាពសំខាន់ៗ

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស រួមទាំងការវាយតម្លៃ និងការវិភាគ ដើម្បីផ្តល់ព័ត៌មានអំពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំ ដើម្បីវឌ្ឍនភាពនៃសមធម៌សុខភាពសម្រាប់ជនមានពិការភាព ពង្រឹងការស្តារលទ្ធភាពពលកម្មក្នុងប្រព័ន្ធសុខាភិបាល និងអនុញ្ញាតឱ្យមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យានៃគ្រឿងជំនួយកាន់តែច្រើននៅកម្ពុជា។
- គាំទ្រដល់ការអភិវឌ្ឍ ការអនុវត្ត និងការពិនិត្យតាមដាន និងការវាយតម្លៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បី ដើម្បីវឌ្ឍនភាពសមធម៌សុខភាពសម្រាប់ជនមានពិការភាពក្នុងវិស័យសុខាភិបាល ពង្រឹងស្តារលទ្ធភាពពលកម្មក្នុងប្រព័ន្ធសុខាភិបាល និងធ្វើឱ្យ លទ្ធភាពទទួលបាននូវបច្ចេកវិទ្យានៃគ្រឿងជំនួយនៅកម្ពុជាមានកាន់តែច្រើន។
- ការធ្វើសមាហរណកម្មនៃបរិយាបន្នពិការភាព និងការពិចារណាលើការស្តារលទ្ធភាពពលកម្ម និងលទ្ធភាពទទួលបានបច្ចេកវិទ្យានៃគ្រឿងជំនួយ ទៅក្នុងយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ និងការពង្រឹងប្រព័ន្ធភាពធន់ ឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសាកល (UHC) ដែល WHO បានផ្តល់ការគាំទ្រដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស រួមទាំងជាផ្នែកមួយនៃការថែទាំសុខភាពបឋម និងការត្រៀមលក្ខណៈសង្គ្រោះផ្នែកសុខភាព និងការឆ្លើយតបបន្ទាន់។
- សហការ និងចូលរួមយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត និងអ្នកចូលរួមគាំទ្រសំខាន់ៗក្នុងវិស័យពាក់ព័ន្ធក្នុងប្រទេសកម្ពុជា (រួមមានម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នតំណាង វិស័យឯកជន និងអង្គភាពស្រាវជ្រាវផ្សេងៗ)

## អ្នកទទួលផល

ជនមានពិការភាពនៅប្រទេសកម្ពុជា និងប្រជាជនដែលត្រូវការ និងទទួលសេវាស្តារលទ្ធភាពពលកម្ម និងបច្ចេកវិទ្យានៃគ្រឿងជំនួយដែលចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវ សុខភាព ដំណើរការមុខងារ និងសុខុមាលភាពរបស់ពួកគេ។

| តំបន់គោលដៅ |
| --- |
| ប្រទេសកម្ពុជា |

| ដៃគូរបស់គម្រោង |
| --- |
| • រាជរដ្ឋាភិបាលកម្ពុជា (ជាពិសេសក្រសួងសុខាភិបាល) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម<br>• ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT)<br>• ជនមានពិការភាព និងអង្គការតំណាងរបស់ពួកគាត់នៅក្នុងប្រទេសកម្ពុជា រួមទាំងអង្គការជនពិការកម្ពុជា (CDPO) និងមូលនិធិជនមានពិការ (PWDF)<br>• ទីភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងទៀតរួមមាន UNFPA UNDP និង UNICEF<br>• ដៃគូអភិវឌ្ឍន៍ផ្សេងទៀតរួមមាន អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គការសម្រាប់ការសិក្សា |

| រយៈពេលអនុវត្ត |
| --- |
| ពីខែមិថុនា ឆ្នាំ២០២៤ ដល់ខែធ្នូ ឆ្នាំ២០២៧ |

| ព័ត៌មានទំនាក់ទំនង | |
| --- | --- |
| អង្គការសុខភាពពិភពលោក ប្រចាំនៅកម្ពុជា<br>វេជ្ជបណ្ឌិត Tomoko ONODA<br>ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៦ ៦១០<br>អ៊ីមែល៖ onodat@who.int | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីមែល៖ vivath.chou@access2cambodia.org |

គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2) ។

ខែមេសា ឆ្នាំ២០២៤